ព្រះរាជាណាចក្រ កម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ................
.......................

លេខ:...៤១.............វ.ក.

រាជធានីភ្នំពេញ. ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៩៦

# សេចក្ដីសំរេច

## ស្ដីពីការកំណត់តំបន់ទាំងបី ..ដើម្បីការពារបេតិកភណ្ឌជាតិ . ...
## នៅតាមបណ្ដាខេត្ត-ក្រុង ក្រៅពីតំបន់អង្គរសៀមរាប

---

## ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

បានឃើញ:- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- ក្រឹត្យច្បាប់លេខ ២១ ក្រច ចុះថ្ងៃទី ១៨ ខែ មិនា ឆ្នាំ ១៩៨៥ ស្ដីពីការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ រមណីយដ្ឋាន វិមានវប្បជាតិ របស់ក្រុមប្រឹក្សារដ្ឋ ។
- ព្រះរាជក្រឹត្យលេខ ០០១ សសរ ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្ដីពីការកំណត់ និង បែងចែកគ្រប់គ្រងតំបន់សៀមរាបអង្គរ របស់ព្រះបាទសម្ដេច ព្រះនរោត្តម សីហនុវរ្ម័ន រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី ។
- ច្បាប់បម្លងស្ដីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ លេខ ៣៧ ចល ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ របស់អគ្គលេខាធិការរាជរដ្ឋាភិបាល ។

តាមរយៈ:- ស្មារតីអង្គប្រជុំរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ស្ដីពីការកំណត់ និង ការចាត់ចែងគ្រប់គ្រងថែរក្សាការពារប្រាសាទទាំងឡាយនៅតាមបណ្ដាខេត្ត-ក្រុងទូទាំងប្រទេស

## សំរេច

ប្រការ ១ :- បង្កើតការកំណត់ និង ការចាត់ចែងគ្រប់គ្រងថែរក្សាការពារប្រាសាទបុរាណ ទីតាំង ស្ថានីយ៍ប្រវត្ត និង បុរេប្រវត្តិ និង រមណីយដ្ឋានប្រវត្តិសាស្ត្រ ជាបីតំបន់:

✓ក- <u>តំបន់ទី ១</u> :- ជាតំបន់ប្រាសាទ ។

- ហាមប៉ះពាល់ដាច់ខាត។ ត្រូវបានកំណត់ ព្រំប្រទល់ចំងាយ ៣០ម៉ែត្រ ពីកំពែងខាងក្រៅរបស់ប្រាសាទ ។ បើមានស្រះព័ទ្ធ ជុំវិញប្រាសាទ ត្រូវកំណត់ចម្ងាយ.

Scanned with CamScanner

៣០ម៉ែត្រ ពីមាត់ស្រះខាងក្រៅរបស់ប្រាសាទ ។ តំបន់នេះ មិនអោយមានដាំដើមឈើទេ ចៀសវាងឈើដួលរលំសង្កត់លើកំពែងប្រាសាទ ។

ខ- <u>តំបន់ទី ២</u> :- ជាតំបន់ឧទ្យានបុរាណវិទ្យា ។

- ត្រូវការពារថែរក្សា ។ តំបន់ នេះ ត្រូវបានកំណត់បរិវេណចម្ងាយ ៣<u>០០</u>ម៉ែត្រពីព្រំប្រទល់តំបន់ ១ ។

គ- <u>តំបន់ទី ៣</u> :- ជាតំបន់ត្រូវប្រើប្រាស់ដីធ្លីតាមបទបញ្ញត្តិ ។ មានព្រំប្រទល់ចម្ងាយ ១៥០០ម៉ែត្រពីក្រៅកំពែងប្រាសាទ ឬ ១<u>៥០០</u>ម៉ែត្រពីមាត់ស្រះព័ទ្ធជុំវិញខាងក្រៅ ។

- ព្រំប្រទល់បរិវេណខាងក្រៅនៃតំបន់ ៣ ត្រូវត្រួសត្រាយធ្វើផ្លូវដែលមានទំហំទទឹង ៥ម៉ែត្រព័ទ្ធជុំវិញ ដើម្បីកំណត់ព្រំប្រទល់បរិវេណប្រាសាទផ្នែកខាងក្រៅផ្លូវព័ទ្ធជាតំបន់របស់ការិយាល័យរុក្ខាប្រមាញ់ខេត្ត-ក្រុង ។

- រមណីយដ្ឋាន ទីតាំង ស្ថានីយ៍បុរេប្រវត្តិ និង ប្រវត្តិសាស្ត្រផ្សេងៗ ត្រូវកំណត់ផ្ទៃបរិវេណ ៥០០ម៉ែត្រព័ទ្ធជុំវិញ ។

ប្រការ ២ :-

<u>តំបន់ ១</u> :- ជាតំបន់ត្រូវថែរក្សាការពារ ដាច់ខាតមិនអោយមានការប៉ះពាល់រុករានគាស់កកាយឡើយ ទោះជានៅលើអាកាស លើផ្ទៃដី ក៏ដូចជានៅក្រោមដី ។

- មិនអោយមានដើមឈើដុះនៅក្នុងតំបន់នេះ ចៀសវាងពេលមានបាក់ពុកផ្សេងៗ ធ្វើអោយខូចខាតដល់ប្រាសាទបុរាណ ។

- ហាមធ្វើការហោះហើរយន្តហោះគ្រប់ប្រភេទលើតំបន់នេះ ។

- ហាមយកសំភារៈសំណង់ប្រាសាទ ដូចជាថ្ម ឥដ្ឋ ឬ វត្ថុសិល្បៈ ក្បូរក្បាច់ខូចក្រឡ ចេញពីកន្លែងដើម ។ អាចយកចេញបាន លុះត្រាតែស្ថិតក្នុងករណីពិសេស និង មានការអនុញ្ញាតពីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

- ហាមសាងសង់សំណង់តូច-ធំគ្រប់ប្រភេទនៅក្នុងតំបន់នេះ ។

- ហាមធ្វើការត្រួសត្រាយ គាស់កកាយរៀរ ធ្វើចំការ ឬដាំដំណាំផ្សេងៗ ។

- ហាមឃ្វាល ចង ឬ លែងសត្វពាហនៈក្នុងបរិវេណនេះ ។

- ហាមធ្វើអាជីវកម្ម សេវាកម្ម លក់ដូរ នៅក្នុងបរិវេណប្រាសាទ ព្រោះតំបន់នេះក៏ត្រូវថែរក្សាការពារដូចតួប្រាសាទដែរ ។

- ហាមបើកបរយានយន្តតូច-ធំលើសពីល្បឿន ៣០ គម ក្នុងមួយម៉ោង ដែលបានកំណត់ក្នុងមាត្រា ៨៣ នៃក្រិត្យច្បាប់លេខ ២១ ក្រ ចុះថ្ងៃទី ១៨ មិនា ១៩៨៥ របស់ក្រុមប្រឹក្សារដ្ឋ ។

- រថយន្តទាំងអស់ ត្រូវចតក្នុងចំណតដែលនាយកដ្ឋានបេតិកភ័ណ្ឌបានកំណត់ទុក

<u>តំបន់ ២</u> :- ជាតំបន់ត្រូវធ្វើការថែរក្សា ការពារ និង ហាមឃាត់ដូចខាងក្រោម:-

- ហាមប៉ះពាល់ដល់សម្បត្តិធម្មជាតិ ព្រៃឈើ និង បេតិកភ័ណ្ឌវប្បធម៌នៅក្នុងតំបន់នេះ ។

Scanned with CamScanner

- ហាមធ្វើកំណាយផ្សេងៗ ។ អាចធ្វើបាន លុះត្រាតែមានការអនុញ្ញាតិពីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈជាមុនសិន ។
- ហាមកាប់គាស់រានដី ដើម្បីប្រកបរបរកសិកម្ម និង សិប្បកម្មផ្សេងៗ ។
- ហាមសាងសង់លំនៅដ្ឋាន ឬ សំណង់សាធារណៈនៅក្នុងតំបន់ ។ អាចសង់បាន លុះត្រាតែមានការអនុញ្ញាតិពីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈសិន ។
- ត្រូវបំផុសការដាំដុះដើមឈើជាលក្ខណៈធម្មជាតិឡើងវិញ ដើម្បីជារបាំងការពារខ្យល់ព្យុះផ្សេងៗ ដែលប៉ះប៉ងដល់ប្រាង្គសិលា ។

<u>តំបន់ ៣</u> :- ជាតំបន់ដែលត្រូវរក្សាទុកជារមណីយដ្ឋាន និង ជាឧទ្យានសំរាប់ការការពារបរិស្ថានប្រវត្តិសាស្រ្ត និង បុរាណវិទ្យា ។

- ជាតំបន់ថែរក្សាការពារមិនអនុញ្ញាតិអោយមានកម្មសិទ្ធិដីធ្លី និង កេរ្តិ៍មរតករបស់ឯកជនឡើយ ។
- ក្នុងករណីដែលមានកម្មសិទ្ធិដីធ្លី ឬ មានការសាងសង់លំនៅដ្ឋានរួចហើយនោះ ត្រូវរក្សាទុកនៅដដែលសិន តែដាច់ខាតមិនអោយពង្រីកកម្មសិទ្ធិបន្ថែម ឬ តាំងទីលំនៅថ្មី ឬ លក់ដូរ និង ផ្ទេរកម្មសិទ្ធិឡើយ ។
- វត្ត អារាម នៅក្នុងបរិវេណប្រាសាទ ដាច់ខាតមិនអោយពង្រីក ឬគាស់កកាយនៅក្នុងតំបន់នេះឡើយ ។ ត្រូវរក្សាភាពដើមសិន ។
- ត្រូវរក្សាការពារព្រៃឈើគ្រប់ប្រភេទអោយបានគង់វង្ស និងចំរាត់ល្អ សំរាប់ជារបាំងការពារខ្យល់ព្យុះសង្ឃរាផ្សេងៗ ដែលប៉ះប៉ងយាយីដល់ប្រាង្គប្រាសាទបុរាណ ។ ដាច់ខាតមិនអោយដាំដើមប្រេងខ្យល់ ឬ ដើមអាកាស្យា ក្នុងតំបន់ ។
- សម្បត្តិធម្មជាតិ ដែលមាននៅក្នុងតំបន់ ត្រូវថែរក្សាការពារ និង ត្រូវដាំដុះថ្មីបន្ថែម ជារៀងរាល់ឆ្នាំ ។ ការដាំដុះនេះ ត្រូវបែងចែកអ្នកទទួលខុសត្រូវលើការដាំដុះ និង ថែរក្សាការពារកូនឈើអោយបានល្អ ។
- ហាមសាងសង់សំណង់ថ្មីនៅក្នុងតំបន់ ។ លើកលែងតែមានករណីពិសេស ដែលមានការអនុញ្ញាតិពីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ហើយសំណង់នោះមិនអោយហួសពី ៦ ម៉ែត្រ ។ ត្រូវធ្វើបង្គោលសីមាដាក់ឈ្មោះប្រាសាទរមណីយដ្ឋាន ។
- ត្រូវបោះបង្គោល ដាក់ផ្លាកសំគាល់បរិវេណប្រាសាទនៅគ្រប់ទិស ដើម្បីកំណត់ព្រំប្រទល់ ងាយស្រួលដល់ប្រជារាស្ត្រគ្កាប់ជាប់ ។

ប្រ ក ា រ ៣ :- ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ អភិបាលខេត្ត-ក្រុង និង អង្គភាពអភិរក្សប្រាសាទបុរាណនៅតាមខេត្ត-ក្រុង ត្រូវសហការណែនាំ បំផុស អប់រំប្រជារាស្ត្រដែលរស់នៅតំបន់ អោយយល់ពីការអនុញ្ញាតិអោយការរស់នៅក្នុងតំបន់នេះ និង យល់ពីភារកិច្ច និង កាតព្វកិច្ចរបស់ប្រជារាស្ត្រម្នាក់ៗ គ្រួសារនិមួយៗ ចូលរួមថែរក្សាការពារ និង ឈប់បំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ និង សម្បត្តិធម្មជាតិ ដូចជាការកាប់គាស់រានដី ធ្វើស្រែចំការ ដុតធ្យូង កាប់ឈើដុតយកជ័រក្នុងតំបន់ហាមឃាត់ ។

- ចំពោះប្រជារាស្ត្រថ្មី គ្រួសារថ្មីដែលទើបនិងមកតាំងទីលំនៅថ្មីនៅក្នុងខេត្ត-ក្រុង អភិបាលខេត្ត-ក្រុង ត្រូវមានផែនការរៀបចំតាមការកំណត់របស់ខេត្ត-ក្រុង ដោយធ្វើយ៉ាងណាមិនអោយប៉ះពាល់ដល់តំបន់ដែលត្រូវការពារ និង ចៀសវាងការមានទស្សនៈរបស់ប្រជារាស្ត្រដែលបើកភ្លែកឡើងសំឡឹងឃើញតែ ឈើ ផ្កា វល្លិ និង ជីកកនដីដាំដំណាំផ្សេងៗនៅក្នុងតំបន់ហាមឃាត់ ។

ប្រការ ៤ :- ការគ្រប់គ្រងប្រាសាទ និង ព្រៃឈើ នៅក្នុងតំបន់ទាំងបី ជាសមត្ថកិច្ចរបស់អង្គការអភិរក្សប្រាសាទបុរាណ និង នាយកដ្ឋានបេតិកភ័ណ្ឌ ។ ប៉ុន្តែការកាត់ក័ន្ទ ដល់បរទូតទេសព្រៃឈើ ត្រូវពិភាក្សាជាមួយក្រសួងកសិកម្ម ឬ មន្ទីរកសិកម្មខេត្តក្រុង តាមខ្លឹមសារក្រឹត្យ-ច្បាប់លេខ ៣៥ ក្រច ចុះថ្ងៃទី ២៥ មិថុនា ១៩៨៨ និង ក្រឹត្យច្បាប់លេខ ២១ ក្រច ចុះថ្ងៃទី ១៨ មិនា ១៩៨៥ ស្តីពីការគ្រប់គ្រងបេតិកភ័ណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ មរណភ័យដ្ឋាន វិមានធម្មជាតិ របស់ក្រុមប្រឹក្សារដ្ឋ ។

ប្រការ ៥ :- អគ្គនាយកខុទ្ទកាល័យ អគ្គនាយកបេតិកភ័ណ្ឌវប្បធម៌ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ អភិបាលខេត្ត-ក្រុង ក្រសួងកសិកម្ម ក្រសួងទេសចរណ៍ ក្រសួងការពារប្រទេស ក្រសួងមហាផ្ទៃ ក្រសួងធម្មការ និង កិច្ចការសាសនា និង ក្រសួងផ្សេងៗដែលមានការពាក់ព័ន្ធ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាពខ្ពស់ ។

ប្រការ ៦ :- សេចក្តីសំរេចនេះ ចូលជាធរមានដៃច្បាប់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
រដ្ឋលេខាធិការ

ស៊ីសុវត្ថិ ស៊ីរីទេ ប៉ុណាក